**<u>ការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ</u>**
**<u>ស្តីពីច្បាប់បរិស្ថាន</u>**

សម្មតិកម្មៈ **<u>ចម្ការកាហ្វេ</u>**

1. នៅឆ្នាំ២០០៧ មានពាណិជ្ជកម្មចម្ការកាហ្វេមួយឈ្មោះ ចម្ការកាហ្វេ បានចាប់ផ្តើមដំណើរការនៅក្បែរភូមិថ្មី។ ចម្ការនោះមានទីតាំងនៅជិតអូរធំ។ ចម្ការកាហ្វេមួយនេះ មានបុគ្គលិក២៥នាក់ ដែលជារបរដែលផ្តល់ការងារច្រើនជាងគេក្នុងតំបន់។

2. នៅមិនឆ្ងាយប៉ុន្មាន តាមដងអូរពីចម្ការកាហ្វេចុះមកក្រោម មានប្រជានជនស្នាក់នៅចំនួនពី២០ ទៅ ៣០ គ្រួសារ ជាសហគមន៍មួយឈ្មោះ ភូមិព្រៃ ហើយចុះមកក្រោមទៀតនៃអូរដែលមានកសិដ្ឋានចិញ្ចឹមគោយកទឹកដោះចំនួន១៥ក្បាល។

3. អ្នកស្រុកភូមិព្រៃនៅតាមដងអូរផ្នែកខាងក្រោមនៃចម្ការកាហ្វេ ប្រើប្រាស់ទឹកពីអូរធំនេះជាទឹកផឹក ហើយកសិដ្ឋានសត្វគោ ក៏ប្រើប្រាស់ទឹកពីអូរធំជាទឹកផឹកដែរសម្រាប់គោដែលត្រូវយកទឹកដោះ និងដាំដំណាំស្រូវ។

4. ចម្ការកាហ្វេ មានផ្ទៃដីសរុបចំនួន ៥០.៤៦ ហិចតា ហើយតែងប្រើប្រាស់ថ្នាំកសិកម្ម (ថ្នាំសម្លាប់សត្វល្អិត) ជាប្រចាំ និងប្រើប្រាស់ជីដើម្បីដាំបាននូវគ្រាប់កាហ្វេដែលមានប្រជាប្រិយភាព។ ការប្រើប្រាស់ប្រភេទគីមីទាំងនេះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។ ជាលក្ខខណ្ឌមួយនៃប្រតិបត្តិការ និងដោយស្របតាមច្បាប់ ចម្ការកាហ្វេ តម្រូវឲ្យ ប្រើប្រាស់គីមីទាំងអស់ដោយមិនឲ្យមានការបំពុលដល់អូរដែលមាននោះទេ។

5. នៅខែកក្កដា ឆ្នាំ២០១៤ ខ្យល់ព្យុះដំរីដែលនៅសល់បានទម្លាក់ភ្លៀងមួយមេយ៉ាងធំមកលើភូមិថ្មី និងតំបន់ដែលនៅជុំវិញ។ នៅមុនភ្លៀងធ្លាក់ ២៤ម៉ោង នោះ កសិកម្មចម្ការកាហ្វេ បានប្រើប្រាស់ថ្នាំកសិកម្មយ៉ាងច្រើនទៅលើដំណាំកាហ្វេ។ អូរធំ ដែលតាមធម្មតាមានលំហូរទឹកតិចៗនោះ បានប្រែជាមានចរន្តទឹកហូរយ៉ាងលឿន ហើយខ្លាំងលិចច្រាំង។ ទម្រាំតែខ្យល់ព្យុះដំរីបានកន្លងផុតទៅ ក៏មានល្បប់ជាច្រើន ហើយថ្នាំកសិកម្មដែលបានប្រើក៏ហូរច្រោះចេញពីចម្ការ ហើយបានហូរទៅ

ធ្លាក់កាន់អូរធំ។

6. បន្ទាប់ពីទឹកស្រកទៅវិញ ក្រុមគ្រួសារជាច្រើនដែលបានរស់នៅក្នុងភូមិព្រៃ នៅផ្នែកខាងក្រោមនៃអូរ បានសម្គាល់ឃើញថា ផ្ទៃដីរបស់ពួកគេពោពេញទៅដោយជានស្នាមគ្រាប់កាហ្វេ និងល្បប់ដែលបានពីអូរនេះ។

7. វាលស្មៅដែលស្ថិតនៅជាប់ចម្ការ ដែលជាកន្លែងគោស៊ីស្មៅ ក៏មានជានល្បប់ចេញពីអូរនេះដែរ ហើយគោទាំងនោះក៏នៅតែបន្តស៊ីស្មៅនៅឡើយបន្ទាប់ពីខ្យល់ព្យុះបានកន្លងផុតទៅ។ វាលដីនៅជិតនោះដែរ ដែលកសិករបានដាំស្រូវក៏ឃើញមានល្បប់ដែលបានពីអូរនោះដែរ។ ដំណាំស្រូវភាគច្រើននៅលើផ្ទៃដីចំនួន ៣ ហិចតា ក៏ប្រែជាស្រពោន ហើយងាប់ទៅៗ។

8. ក្រោយពីខ្យល់ព្យុះបានកន្លងផុតទៅ អ្នកស្រុកភូមិព្រៃ បានឃើញថា ទឹកបរិភោគរបស់ពួកគេប្រែជាមានរស់ជាតិក៏អាក្រក់។ មនុស្សក៏ចាប់ផ្ដើមឈឺ ហើយមានត្រីរាប់តោនបានងាប់គនៅលើច្រាំងនៃអូរ។ ពួកគេក៏បានសំណូមពរឲ្យក្រសួងបរិស្ថានបញ្ជូនមន្ត្រីអធិការកិច្ចឲ្យចុះមកធ្វើការពិសោធទឹក។

9. ក្រសួងបរិស្ថាន បានបញ្ជូនមន្ត្រីអធិការកិច្ចលោក សុខា សុធា ដែលជា វិស្វករផ្នែកបរិស្ថានដែលមានការបញ្ជាក់ត្រឹមត្រូវ មកធ្វើការពិសោធទឹក និងពិនិត្យមើលក្រែងប្រជាជនដែលរស់ក្នុងភូមិព្រៃកំពុងរងនូវគ្រោះថ្នាក់ផ្នែកសុខភាពដទៃណាទៀត ដោយសារការហូរចេញនៃអូរ។ មន្ត្រីអធិការកិច្ចលោក សុខា បានយកសំណាកទឹកពីកន្លែងរស់នៅជាច្រើននៅជុំវិញភូមិព្រៃ ដែលជាកន្លែងដែលគ្របដណ្ដប់ទៅដោយល្បប់នៃអូរ។

10. មន្ត្រីអធិការកិច្ចលោក សុខា បានបញ្ជូនសំណាកទឹក និងសំណាកដីទៅកាន់មន្ទីពិសោធន៍ ដែលក្រសួងបានបញ្ជាក់ថា បានទទួលសិទ្ធិក្នុងការធ្វើការវិភាគទៅលើការពិសោធ។ ចំណុចវិភាគអំពីសំណាកទឹកដែលបានពីកន្លែងស្នាក់នៅ បានបង្ហាញថា ទឹកបរិភាគនោះមានថ្នាំកសិកម្មដែលហួសពីកម្រឹតអតិបរិមា ២០០ % ។ ការវិភាគនៃសំណាកទឹកដែលបានពីអូរធំ ដែស្ថិតនៅជិតបំពង់បង្ហូរទឹកបរិភោគនៃភូមិព្រៃ បានបង្ហាញថា ទឹកហូរនោះនៅជាទឹកដែលពុលនៅឡើយដែលមានកម្រឹតនៃការបំពុល ៥០ % ខ្ពស់ជាងកម្រឹតអតិបរមាដែលបានអនុញ្ញាតឲ្យប្រើប្រាស់។ មន្ត្រីអធិការកិច្ចលោក សុខា បានជឿថា ថ្នាំគីមី បានហូរចូលទៅតាមបំពង់បង្ហូរទឹកបរិភោគ និងបានបង្ករឲ្យមានកម្រឹតថ្នាំកសិកម្មកើនឡើងខ្ពស់នៅពេលទឹកនោះហូរទៅដល់កន្លែងប្រជាជនរស់នៅ ជាង

ពេលដែលទឹកនោះនៅក្នុងអូរនៅឡើយ។ លោក ជឿថា អ្នកភូមិ ភូមិព្រៃ ច្បាស់ជាបាននឹងកំពុងបរិភោគទឹកដែលបានពីអូរឬទឹកដែលបានពីរ៉ូម៉ីននៅតាមផ្ទះរបស់ពួកគេហើយ។

11. ការវិភាគទៅលើសំណាកដី ដែលមន្ត្រីអធិការកិច្ចបានបមូលយកពីទីធ្លាដីអ្នកស្រុក នៅក្នុងភូមិព្រៃ បានបង្ហាញថា សំណាកដីមានកំហាប់នៃថ្នាំគីមីខ្ពស់។ លោក បានគិតថា ដើម្បីសុវត្ថិភាពកុមារៗ ពួកគេមិនត្រូវលេងក្នុងទីធ្លាដីឬប៉ះពាល់ដីនោះទេ។

12. ការប៉ះពាល់ជាមួយនឹងកម្រិតថ្នាំកសិកម្មខ្ពស់ អាចបង្កឲ្យមានផលប៉ះពាល់ដល់សុខភាពរបស់មនុស្ស ជាពិសេសកុមារ។ ការប៉ះពាល់ទាំងនេះ អាចនាំឲ្យខូចដល់សរីរាងខាងក្នុង ដូចជា តម្រងនោម ជាដើម និងទាំងអាចនាំឲ្យខូចខួរក្បាល និងប្រព័ន្ធសសៃប្រសាទ ដល់មនុស្សដែលបានប៉ះពាល់វា។ កុមារដែលប៉ះពាល់គីមីច្រើនក្នុងកម្រិតហួសប្រមាណ នោះអាចបង្កឲ្យមានការកាត់បន្ថយការចងចាំជាអចិន្ត្រៃ និងសមត្ថភាពបញ្ញា។

13. លទ្ធផលនៃការវិភាគទាំងនេះធ្វើឲ្យលោកសុខាមានកង្វល់យ៉ាងខ្លាំង។ គាត់បានទទួលការអនុញ្ញាតពីប្រធាននៅក្នុងក្រសួងបរិស្ថាន ឲ្យពិនិត្យទៅលើសំណល់ថ្នាំកសិកម្ម ដែលបានពីចម្ការកាហ្វេ ក្រែងមានបង្កបញ្ហាសុខភាពឥឡូវ និងពេលខាងមុខ នៅក្នុងតំបន់។ លោក បានចូលទៅក្នុងកសិដ្ឋាន ហើយបានឃើញថា គោសម្រាប់យកទឹកដោះគឺកំពុងស៊ីស្មៅនៅក្នុងវាលស្រែដែលនៅជិតអូរធំ។ មានគោជាច្រើន គេឃើញថាកំពុងឈឺ។ រួចលោកក៏បានយកសំណាកឈាមពីគោទាំងនេះ រួចបញ្ជូនទៅធ្វើការពិសោធន៍នៅក្នុងមន្ទីពិសោធ។ មន្ទីពិសោធ បានបង្ហាញលទ្ធផលថា ក្នុងគោមានជាតិថ្នាំកសិកម្មច្រើននៅក្នុងឈាម ហើយបានកំណត់ថាទឹកដោះគោទាំងនោះ មិនគួយកទៅប្រើប្រាស់សម្រាប់មនុស្សនោះទេ។

14. មន្ត្រីអធិការកិច្ច លោក សុខា ក៏បានឃើញផងដែរថា មានសត្វទាងាប់អណ្តែតនៅក្នុងវាលស្រែ និងត្រីងាប់នៅលើច្រាំងអូរ។ លោកបានស្នើឲ្យវេជ្ជមណ្ឌិត កែវ ចាន់ដារ៉ា ដែលជាសាស្ត្រាចារ្យជីវសាស្ត្រទឹក ឲ្យធ្វើការវិភាគ រកទំនាក់ទំនងនៃការងាប់ត្រី និងទានេះ ទៅកាន់ថ្នាំកសិកម្ម ដែលប្រើដោយចម្ការកាហ្វេ។ បណ្ឌិត ចាន់ដារ៉ា បានឃើញថាមានទាចំនួន១០ក្បាលអណ្តែតងាប់នៅក្នុងវាលស្រែ និងត្រីជាច្រើននៅតាមច្រាំងអូរ។ ការពិសោធទៅលើទា និងត្រីដែលងាប់បង្ហាញថាទាំងពីរសុទ្ធតែមានជាតិថ្នាំកសិកម្មនៅក្នុងឈាម។ លោកបណ្ឌិត ក៏បានធ្វើការអង្កេតទៅលើសត្វទាផ្សេងជាច្រើនទៀតនៅក្នុងវាលស្រែដែលហាក់ជាកំពុងឈឺ។

15. ស្របតាមលទ្ធផលនៃការស្រាវជ្រាវ និងការធ្វើអធិការកិច្ចដំបូង របស់មន្ត្រីអធិការកិច្ចលោក សុខា អ្នកស៊ើបអង្កេតពីក្រសួងបរិស្ថានមានធ្វើការយកសំណាកផ្នែកបរិស្ថានជាច្រើនទៀតនៅក្នុងបរិវេណនៃចម្ការកាហ្វេ និងតំបន់ខាងក្រោម នៃដងអូរធំ។ ក្រសួងក៏បានប្រមូលយកសំណាកដែលនៅក្បែរ និងនៅឯចម្ការកាហ្វេ។

- សំណាកទឹក និងសំណាកល្បប់ដែលបានពីអូរធំភ្លាមៗនៃផ្នែកខាងលើរបស់កសិកម្ម ចម្ការកាហ្វេ មានកម្រឹតថ្នាំកសិកម្មទាបខ្លាំងណាស។
- សំណាកទឹក និងសំណាកល្បប់ដែលបានពីវាលស្រែ បង្ហាញថា មានកម្រឹតថ្នាំកសិកម្មខ្ពស់។
- សំណាកទឹកដែលបានពីអូរធំ ពីបំពង់បង្ហូរទឹកបរិភោគ នៃភូមិព្រៃ បង្ហាញថា មានកម្រឹតនៃថ្នាំកសិកម្មកាន់តែកើនឡើង។

16. បណ្ឌិត កែវ ចាន់ដារ៉ា ជាសាស្ត្រាចារ្យជីវសាស្ត្រទឹក បានជម្រាមដល់មន្ត្រីក្រសួងថា ដោយសារមានកម្រឹតនៃថ្នាំកសិកម្មចេះតែកើន ជាសុវត្ថិភាពមិនត្រូវឲ្យអ្នកភូមិព្រៃបរិភោគទឹកពីអូរធំឡើយ រហូតទាល់តែល្បប់ដែលមានជាតិពុលត្រូវបានដកចេញអស់សិន។ លោក បណ្ឌិត ចាន់ដារ៉ា ក៏បានដើរកាត់តាមដងអូរធំពីចម្ការកាហ្វេ ទៅភូមិព្រៃផងដែរ។ លោកបានឃើញល្បប់ធំៗចំនួន៥ របេះបន្តិចម្តងៗធ្លាក់ចូលទៅក្នុងអូរ។ លោក ចាន់ដារ៉ា គិតថា ល្បប់ធំៗដែលបាក់ចូលទៅក្នុងអូរទាំងនេះ ត្រូវឲ្យមានការរើយកចេញនៅមុនពេលអ្នកភូមិព្រៃអាចបរិភោគទឹកពីអូរនេះបានឡើងវិញ។

17. មន្ត្រីអធិការកិច្ច លោក សុខា បានថតរូបនៃកន្លែងដែលល្បប់ដីនៃចម្ការកាហ្វេបានបាក់ស្រុតចុះចូលទៅក្នុងអូរ។ លើសពីនោះ លោក បាន់ទាំងថតរូបសត្វទាពីរក្បាលដែលបានអណ្តែតងាប់នៅក្នុងវាលស្រែផ្នែកខាងក្រុមនៃដងអូរ។

18. ក្រសួងបរិស្ថានបានរៀបចំរបាយការណ៍មួយដែលបង្ហាញថា អូរនោះមិនអាចប្រើជាប្រភពទឹកបរិភោគបាន សម្រាប់អ្នកស្រុកដែលមានចំនួនពី ២០ ទៅ ៣០ គ្រួសារដែលរស់នៅផ្នែកខាងក្រោមនៃចម្ការកាហ្វេនោះទ រហូតទាល់តែមានការរើចេញនូវល្បប់ដែលមានជាតិពល។ ដូច្នេះ គ្រួសារចំនួនពី ២០ ដល់ ៣០ គ្រួសារនេះត្រូវបរិភោគទឹកដាក់ជាកាដុង ដែលមានតម្លៃ ៩០០ដុល្លាក្នុងមួយខែ។

19. កសិករដែលប្រតិបត្តិការលើកសិដ្ឋានចិញ្ចឹមគោយកទឹកដោះ នៅផ្នែកខាងក្រុមនៃអូរចម្ការកាហ្វេ បានទទួលបញ្ជាពីក្រសួងបរិស្ថាន ហាមមិនឲ្យលក់ទឹកដោះគោរបស់គាត់ឡើយ ដរាបណាជាតិថ្នាំកសិកម្មនៅក្នុងទឹកដោះគោមិនទាន់ធ្លាក់ដល់កម្រិតដែលអាចទទួលយកបាននៅឡើយ។ កសិកររូបនេះ បានអះអាងថា គាត់បានរងការខាតបង់ចំណូលប្រមាណ ១០០ ដុល្លា ក្នុងមួយអាទិត្យពីផ្នែកទឹកដោះគោនេះ។ លើសពីនេះទៅទៀត ដោយគោទាំងនេះពាក់ព័ន្ធទៅនឹងថ្នាំកសិកម្មដោយការស៊ីស្មៅនៅក្នុងវាលដែលបានរងការបំពុលដោយទឹកជំនន់ នោះកសិករត្រូវចំណាយ ៥០ដុល្លា ក្នុងមួយសប្តាហ៍ដើម្បីដឹកគោទាំងនេះទៅស៊ីស្មៅស្អាតនៅភូមិក្បែរៗនោះ។

20. ក្រុមមេធាវី ដំណាងឲ្យចម្ការកាហ្វេ បានរៀបចំផែនការ បដិសេធថា ខាងចម្ការកាហ្វេមិនគួទទួលខុសត្រូវទៅលើការបំពុលអូរធំនោះទឹកនោះទេ ព្រោះខ្យល់ព្យុះទេដែលជាអ្នកបង្ក (ដូច្នេះវាជាករណីប្រធានសក្តិ)។ ក្រសួងបរិស្ថាន គ្រោងនឹងឆ្លើយទៅវិញថា ស្របតាមច្បាប់ស្តីពីថ្នាំកសិកម្មចម្ការកាហ្វេ តម្រូវឲ្យប្រើប្រាស់ថ្នាំកសិកម្មដោយទប់ស្កាត់មិនឲ្យថ្នាំទាំងនោះហូរចូលទៅក្នុងអូរឡើយ ហើយថាករណីខ្យល់ព្យុះគឺជាករណីដែលកើតឡើងជាប្រចាំរដូវ ហើយជាគ្រោះថ្នាក់ដែលអាចព្យាករណ៍បាន។ បន្ថែមលើសពីនេះ ខ្យល់ព្យុះបែបនេះ គឺត្រូវបានព្យាករណ៍មុនកើតហេតុរួចហើយថានឹងនាំឲ្យមានការបាក់ច្រោះដីអស់រយៈពេល៥ថ្ងៃ ។